**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.........០៣៤៦/១៨.........ក.ប/ស.ជ.ណា.ខ.វ

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបរំលឹកជូន ម្ចាស់ ឬនាយក រោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្មផលិតផល និងអាជីវកម្មនានាឱ្យបានជ្រាបថា ទោះបីកន្លងមកការចុះធ្វើអធិការកិច្ចការងារនៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្មផលិតផល និងអាជីវកម្មនានាមិនទាន់រកឃើញការប្រើប្រាស់ការងារដោយបង្ខំ និងពលកម្មកុមារក្តី ម្ចាស់ ឬនាយក រោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្មផលិតផល និងអាជីវកម្មនានា ត្រូវបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់តាមច្បាប់ស្តីពីការងារ និងប្រកាសដែលពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ និងពលកម្មកុមារ ដូចតទៅ៖

១- បន្តប្រឆាំងរាល់ទម្រង់ នៃការកេងប្រវ័ញ្ចពលកម្ម និងហាមឃាត់ដាច់ខាតការប្រើប្រាស់បំណុលនៃទំនាក់ទំនងបុគ្គល និងបំណុលនៃគ្រឹះស្ថានហិរញ្ញវត្ថុមកដាក់បន្ទុកសេរីភាពការងាររបស់កម្មករនិយោជិត ទោះបីក្នុងលក្ខណៈម៉ៅការ ឬកិច្ចសន្យាបន្តក្តី។

២- គ្រប់អាជីវកម្ម សិប្បកម្ម និងសេវាកម្មទាំងអស់ មិនត្រូវប្រើប្រាស់កុមារក្រោមអាយុ១៥ឆ្នាំ។ ដោយឡែកមណ្ឌលកំសាន្តមនុស្សពេញវ័យ ហាមឃាត់ដាច់ខាតការប្រើប្រាស់អនីតិជន (កុមារអាយុក្រោម១៨ឆ្នាំ) និងការជួញដូរកម្លាំងពលកម្ម។

៣- ក្នុងករណីក្រុមអធិការកិច្ចការងាររបស់ក្រសួងរកឃើញនូវកំហុសទាំងនេះ ក្រសួងនឹងធ្វើការផាកពិន័យ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា គ្រប់មន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ អាជ្ញាធរដែនដី ម្ចាស់ ឬនាយក រោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្មផលិតផល និងអាជីវកម្មនានា ខិតខំសហការផ្សព្វផ្សាយ និងអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព៕

ថ្ងៃ សុក្រ ៣កើត ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីសហការ និងអនុវត្ត"
- សមាគមនិយោជក
- សហព័ន្ធសហជីព កម្មករនិយោជិត
  "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩